ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅទីក្រុងហាណូយ អន្តរាគមជួយនារីខ្មែរ៣នាក់

---------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៧ សហការជាមួយនាយកដ្ឋាននគរបានព្រហ្មទណ្ឌនៃក្រសួងនគរបាលវៀតណាម បានអន្តរាគមជួយនារីខ្មែររងគ្រោះចំនួន**៣នាក់** ដូចខាងក្រោម៖

១- កញ្ញា **ហ.ស.ណ** អាយុ២០ឆ្នាំ មកពីស្រុកក្រូចឆ្មា ខេត្តកំពង់ចាម

២- កញ្ញា **ស.ស.ព** អាយុ១៩ឆ្នាំ មកពីស្រុកក្រូចឆ្មា ខេត្តកំពង់ចាម

៣ -កញ្ញា **អ.ស.ង** អាយុ១៨ឆ្នាំ មកពីស្រុកអូរឫស្សី ខេត្តក្រចេះ ។

នារីខ្មែរទាំង៣នាក់ ត្រូវបានមេខ្យល់នាំឆ្លងចូលប្រទេសវៀតណាម កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ និងបន្តធ្វើដំណើរតាមច្រកព្រំដែនវៀតណាម-ចិន Mong Cai នៃខេត្ត Quang Ninh បម្រុងនាំទៅរៀបការជាមួយបុរសជនជាតិចិន នៅប្រទេសចិន ជាថ្នូរនឹងប្រាក់ចន្លោះពី ១៥០០ ដុល្លារ ទៅ ២០០០ ដុល្លារអាមេរិក ។ បច្ចុប្បន្នអ្នកទាំង៣ កំពុងត្រូវបានគាំពារដោយយកចិត្តទុកដាក់ ពីអង្គការ Blue Dragon Children's Foundation ក្នុងប្រទេសវៀតណាម។

ស្ថានទូត កំពុងសហការជាមួយនាយកដ្ឋាននគរព្រហ្មទ័ណ្ឌនៃក្រសួងនគរបាលវៀតណាម និងអង្គការ Blue Dragon Children's Foundation ដើម្បីធ្វើបែបបទបញ្ជូននារីខ្មែរទាំង៣នាក់ ត្រឡប់មកកម្ពុជាវិញក្នុងពេលឆាប់ៗខាងមុខ ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ